**ខ.ការដាំ** ពពួកស្មៅប្រភេទនេះងាយស្រួលក្នុងការដាំណាស់ គេអាចដាំដោយកាត់ដើមរបស់វាឬបំបែកកូន។

**ការដាំដើម:** ករណីនេះត្រូវកាត់ដើមវាជាកង់ៗដោយក្នុងមួយកង់ៗមានបីថ្នាំង។



**ដាំដោយសាបគ្រាប់:** មានពីរបៀប គឺដាំដោយ ព្រោះគ្រាប់ពូជ និង ដាំដោយបំបែកកូន។

**ក.ការដាំដោយព្រោះគ្រាប់:** ក្រោយពីធ្វើដីរួច យកគ្រាប់ទៅត្រាំទឹកឱ្យរីកល្អ រួចរោយគ្រាប់ពូជក្នុងចង្អូរដែលឆ្វូតរួច (ដោយដៃ ឬ កំប៉ុង លុបដី ម៉ត់ពីលើបង្ហាប់ថ្នមៗ)។ ក្រោយពេលព្រោះបាន ២-៣ ថ្ងៃមាន បើមានភ្លៀងដំណុះល្អ តែបើក្រោយពេលព្រោះបានពី ៧-១០ ថ្ងៃ គ្មានភ្លៀងត្រូវស្រោចទឹកឱ្យបានសើមល្អ។

**ខ.ការដាំដោយបំបែកកូន:** ដើម្បីសន្សំកម្លាំងពលកម្មក្នុងការថែទាំស្មៅ យើងមានវិធីសាស្ត្រមួយទៀត គឺសាបពូជស្មៅនៅលើថ្នាលតូចមួយដូចសំណាប។ នៅពេលដែលកូនស្មៅធំល្មម(អាយុប្រហែល ២០-២៥ថ្ងៃ)ទើបយើងចាប់ផ្តើមបំបែកយកទៅដាំ ធ្វើបែបនេះអាចឱ្យយើងមានកូនស្មៅដាំ ពីដើមរដូវភ្លៀង។ តាមការសង្កេត ការដាំដំណាំចំណីសត្វពីផ្នែកលូតលាស់វាមានការលូតលាស់លឿន ងាយស្រួលកំចាត់ស្មៅចង្រៃ មិនពិបាករៀបចំដីឱ្យបានល្អនោះទេ និង ចំណេញពេលវេលា។

**ការថែទាំ** ត្រូវតាមដានការលូតលាស់របស់ស្មៅបោចស្មៅចង្រៃ ជ្រួយដី ដាក់ជីបន្ថែម។ ក្រោយពេលព្រោះ ឬដាំបាន ២-៣ ថ្ងៃមានភ្លៀងដំណុះល្អ បើក្រោយពេលព្រោះ ឬ ដាំបាន ៧-១០ ថ្ងៃ គ្មានភ្លៀងត្រូវស្រោចទឹកឱ្យបានសើមល្អ។

**ការប្រមូលផល** ការប្រមូលផល ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម:

- ✓ រយៈពេលប្រមូលផលលើកទី ១ នៅពេលស្មៅមានអាយុពី ៥០ ទៅ ៦០ថ្ងៃ
- ✓ រយៈពេលប្រមូលផលលើកទី ២នៅពេលស្មៅមាន អាយុ ៣០-៣៥ ថ្ងៃ។ កាត់ដើមកំពស់ពីផ្ទៃដីប្រមាណ ៥-១០ ស.ម។

**ចំណាំ:** មិនគួរផ្តល់ឱ្យសត្វស៊ីតែស្មៅមួយមុខត្រូវលាយជាមួយចំបើង ឬចំណីផ្សេងទៀត ចៀសវាងការរាគរូស។

ឯកសារយោង:


គម្រោងអនុវត្តប្រសើរលើការងារសុខភាព និង ផលិតកម្មគោនៅកម្ពុជា

ACIAR និង CIATសៀវភៅបច្ចេកវិជ្ជាស្មៅដែលកំពុងអភិវឌ្ឍន៍នៅកម្ពុជា

**លន់ សុផល:** (២០០៦)ដំណាចំណីសត្វកំពុងអភិវឌ្ឍន៍ជាមួយកសិករ



នាយកដ្ឋាន

ផលិតកម្ម និង បសុព្យាបាល


# ស្មៅដំរី

Elephant Grass




**រៀបចំដោយ:** ការិយាល័យផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល នៃនាយកដ្ឋានផលិតម្មនិងបសុព្យាបាល

**អាស័យដ្ឋាន:** ផ្លូវសទ្បា ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**ស្ថានភាពទូទៅ**

ពីមុនកសិករចិញ្ចឹមសត្វជាទំលាប់ គឺលែងឱ្យស៊ីដោយសេរី ។ បច្ចុប្បន្នសត្វកើន និងផ្ទៃដីដាំដុះត្រូវបានពង្រីកនាំឱ្យដីវាលចំណីសត្វថយចុះ ។ កសិករមិនអាចលែងសត្វសេរីបានដូចមុនទៀតទេ ។ កសិករភាគច្រើនត្រូវចំណាយពេលស្វែងរកស្មៅ និង ចំណាយថវិកាសំរាប់ទិញស្មៅ ពេលខ្លះការលំបាកខ្លាំងកសិករបង្ខំចិត្តកាត់បន្ថយ ចំនួនសត្វចិញ្ចឹម ។ ដើម្បីដោះស្រាយបញ្ហានេះ **ដំណាំចំណីសត្វ គឺជាដំណោះស្រាយសាមញ្ញ និងសមស្រប មួយសម្រាប់កសិករ ។**

**តើដំណាំចំណីសត្វជាអ្វី** ?

គឺជាពពួកស្មៅ ពពួកលេហ្គឹមវ៉ា និង ពពួករុក្ខជាតិលេហ្គឹម ឬ ចុល្លព្រឹកដែលគេដាំថែទាំ ស្រោចទឹក បោចស្មៅចង្រៃ សម្រាប់ប្រើប្រាស់ជាចំណីសត្វ ។ ពពួកដំណាំចំណីសត្វទាំងនេះ ភាគច្រើនត្រូវបាននាំចូលមកពីបរទេស ហើយដែលត្រូវបានឆ្លងកាត់ការ វាយតម្លៃដោយមានការចូលរួមពីកសិករអ្នកផ្សព្វផ្សាយ និង អ្នកស្រាវជ្រាវដែលមានបទពិសោធន៍ លើផ្នែកនេះលើលក្ខណៈរបស់ដំណាំចំណីសត្វ ដែលសមស្របសំរាប់ដាំនៅតំបន់ត្រូពិក ។ដំណាំចំណីសត្វដែលណែនាំឱ្យកសិករដាំគឺជាប្រភេទចំណី ដែលមានការដុះលូតលាស់លឿន ទិន្នផលខ្ពស់ និង សមស្របទៅនឹងលក្ខណៈសណ្ឋានដី អាកាសធាតុប្រទេសកម្ពុជា និងសំបូរទៅដោយសារធាតុចិញ្ចឹម ។

**គុណប្រយោជន៍នៃដំណាំចំណីសត្វ**

✓ បង្កើនជីជាតិដីតាមរយៈប្រភេទដំណាំចំណីសត្វ និង ជីលាមកសត្វកើនឡើង

✓ ផ្តល់ដល់សត្វនូវបរិមាណ និង គុណភាពចំណីតាមកំរិតអាហារូបត្ថម្ភ

✓ ដំណាំចំណីសត្វ មួយចំនួនអាចជួយគ្រប់គ្រងបរិស្ថានបានល្អប្រសើរ (ជាគម្របដី ការពារដីហូរច្រោះ បង្កើនជីវជាតិដី និង បំផ្លាញស្មៅចង្រៃ)

✓ ចំណេញពេលវេលា និង ថវិកាចំណាយក្នុងការស្វែងរក ឬ ទិញស្មៅសំរាប់សត្វ

✓ ជួយកសិករ ផ្លាស់ប្តូរពីការចិញ្ចឹមសត្វបែបយថាផល

✓ មកមានការគ្រប់គ្រងល្អ ។

ខាងក្រោមនេះយើងនឹងយកលក្ខណៈពិសេស របស់ស្មៅដំណាំចំណីសត្វមួយប្រភេទដែលមាន ឈ្មោះថា **ស្មៅដំរី** (Elephant Grass ) ។

**ស្មៅដំរី** (Elephant Grass) គឺជាប្រភេទដំណាំចំណីសត្វ មានប្រភពមកពីប្រទេសអាហ្វ្រិក ដែលនាំចូលមកស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ នៅឆ្នាំ ១៩៨៥ ដោយអង្គការ LWS ។ ជាស្មៅមានដើមខ្ពស់ មានប្រូតេអ៊ីនពី ១៥-១៦ % អាស៊ូត ១,៦- ២,២% សារធាតុស្ងួតដែលអាចរលាយបាន ៥០-

✓ ៦៥% (ស្មៅស្ងួត) ។ទិន្នផលជាមធ្យមនូវរដូវវស្សាពី ២៥ ទៅ ៣០ តោន ស្មៅស្រស់/ម្តង/ហ.ត និង រដូវប្រាំងពី ៧ ទៅ១០តោនស្មៅស្រស់/ម្តង/ហ.ត ។ គុណភាពនិងទិន្នផលស្មៅអាច ប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រដីជីវជាតិរបស់ដី និងអាយុរបស់ស្មៅ ។



**បច្ចេកទេសដាំ**

**ក.ការរៀបចំដី**

✓ ត្រូវជ្រើសរើសដីមិនលិចទឹក ឬ មិនដក់ទឹកពេក

✓ ត្រូវរៀបចំដីឱ្យបានស្អាតល្អ ដោយភ្ជួរដីឱ្យបានជ្រៅភ្ជួរ ២-៣ ដង មុនពេលដាំ ១៤ ថ្ងៃ

✓ រាស់បំបែកដីឱ្យបានម៉ត់ល្អ សំអាតស្មៅចង្រៃ និងផ្ទៃដីធ្វើឱ្យបានរាបស្មើ (ងាយដាំដុះ បំប៉ន ស្រោចទឹក)

✓ ឆូតរងជាជួរជំរៅ ២-៣ សម ចន្លោះរង ០,៤ម ដាក់ជីទ្រាប់បាទ(ជីអាចមិគោ ឬជីកំប៉ុស្ត) ។



ការរៀបចំដីសម្រាប់ដាំដំណាំចំណីសត្វ